# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-May-2013, 15:49
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជតក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# បណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងនៅនឹងសេចក្ដីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម មុ៉ង មុនីចរិយា

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា អ៊ូច ស្រីផាត់

លោកស្រី សុគន្ធ មោនីកា

កញ្ញា Blandine ZELLER

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានបដិសេធសំណើសុំដោះលែងឱ្យនៅក្រៅឃុំលើកដំបូង ដែលបានដាក់ដោយលោក ខៀវ សំផន[1]។

២. នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សម្អាងហេតុក្នុងសេចក្តីសម្រេចរបស់ខ្លួន ប៉ុន្តែបែរជាតម្កល់ការបដិសេធសំណើសុំទៅវិញ[2]។

៣. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ តុលាការកំពូលបានប្រកាសអសុពលភាពការបំបែកសំណុំរឿងក្នុងរឿងក្តី ០០២ ហើយបានលើកឡើងអំពីព្យសនកម្មដែលភាគីបានទទួលរង[3]។

៤. នៅថ្ងៃទី ១៨ ២០ និង ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបើកសវនាការសម្រេចអំពីផលវិបាកនៃសេចក្តីសម្រេចរបស់តុលាការកំពូល[4]។ នៅក្នុងអំឡុងពេលសវនាការនោះ មេធាវីការពារក្តីលោក ខៀវ សំផន បានប្រកាសដាក់សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ[5]។

---

[1] សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ **E50** ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១")។

[2] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **E50/3/1/4** ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន")។

[3] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E163/5/1/13** ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី")។

[4] ប្រតិចារឹកសវនាការ ("ប្រតិចារឹក") ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/171.1**, ប្រតិចារឹក ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/172.1**, ប្រតិចារឹក ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/173.1**។

[5] ប្រតិចារឹក ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/172.1** ទំព័រ ៧៨-៧៩ (ភាសាបារាំង)។

៥. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ មេធាវីការពារក្ដីបានដាក់សំណើសុំនោះ[6]។

៦. នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្ដីលោក ខៀវ សំផន បានស្នើសុំឱ្យដាក់បញ្ចូលឯកសារដកស្រង់នានាចេញពីសៀវភៅរបស់លោកចៅក្រមស៊ើបអង្កេត Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ដែលពាក់ព័ន្ធនឹងសំណើសុំដោះលែងឱ្យនៅក្រៅឃុំ[7]។

៧. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ នៅក្នុងអំឡុងសវនាការដែលពាក់ព័ន្ធនឹងសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំ អង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងទៅក្នុងកិច្ចពិភាក្សាដេញដោលឡើយ។ អង្គជំនុំជម្រះថែមទាំងបានបញ្ជាក់ថាសំណើសុំនេះត្រូវតែបានអនុវត្តតាមនីតិវិធីដូចប្រក្រតីរបស់ខ្លួន ហើយភាគីនីមួយៗអាចធ្វើកំណត់សម្គាល់របស់ខ្លួនបាន[8]។

៨. ដោយឡែក នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣ តាមរយៈលិខិតមួយរបស់ក្រឡាបញ្ជីឆ្លើយតបទៅកាន់សហព្រះរាជអាជ្ញា ភាគីត្រូវបានជូនដំណឹងថា អង្គជំនុំជម្រះនឹងទុកសំណើសុំនោះថាគ្មានកម្មវត្ថុ[9]។

៩. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចថ្មីរបស់ខ្លួនពាក់ព័ន្ធនឹងការបំបែកសំណុំរឿង[10] ព្រមទាំងសេចក្ដីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងសំណើសុំដោះលែងឱ្យនៅក្រៅឃុំរបស់លោក ខៀវ សំផន[11]។

---

[6] សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E275** (“សំណើសុំដោះលែងឱ្យនៅក្រៅឃុំ”)។

[7] សំណើលើកទី១ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E280**។

[8] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/180.1** ទំព័រ ៨៩ បន្ទាត់ ១១-១៩ (ភាសាបារាំង)។

[9] អ៊ីមែលរបស់លោក Roger PHILLIPS កម្មវត្ថុ៖ « *Re: Forms of Response to Khieu Samphan's Rule 87 (4) Application* » ផ្ញើថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣ វេលាម៉ោង ១៥ និង ១៥ នាទី ឯកសារ **E280/1**។

[10] *សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ*

១០. នាពេលនេះ មេធាវីការពារក្ដីលោក ខៀវ សំផន សូមដាក់បណ្ដឹងសាទុក្ខប្រឆាំងទៅនឹងសេចក្ដីសម្រេចបដិសេធសំណើសុំដោះលែងឲ្យនៅក្រៅឃុំ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ[12] (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”) ។

១១. ជាក់ស្ដែង នៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានវាយតម្លៃថា រយៈពេលឃុំខ្លួនបណ្ដោះអាសន្នជាង ៥ ឆ្នាំ ដែលលោក ខៀវ សំផន បានទទួលរង ពុំមែនជារយៈពេលមួយដែលហួសហេតុនោះទេ។ បើតាមការយល់ឃើញរបស់អង្គជំនុំជម្រះ ស្ថានភាពរបស់ជនជាប់ចោទមិនត្រូវបានផ្លាស់ប្ដូរឡើយ ចាប់តាំងពីពេលដែលមានការបដិសេធលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំចុងក្រោយរបស់ខ្លួនកាលពីឆ្នាំ ២០១១ នោះ។

១២. នាពេលនេះ មេធាវីការពារក្ដីនឹងបង្ហាញថា អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសឆ្គងជាច្រើនដែលជាហេតុធ្វើឲ្យសេចក្ដីសម្រេចរបស់ខ្លួនទទួលរងនូវមោឃភាព។

## ១. ឧឡារិកករណ៍នៃការរក្សាបន្តឃុំខ្លួនបណ្ដោះអាសន្ន

១៣. នៅត្រង់កថាខណ្ឌ ២១ នៃសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានប្រកាសថាហានិភ័យនៃការរត់គេចខ្លួន និង/ឬការយឺតយ៉ាវនៃកិច្ចដំណើរការនីតិវិធី ក្នុងករណីដែលលោក ខៀវ សំផន មិនបានបង្ហាញខ្លួនចំពោះមុខតុលាការ ជាមូលហេតុសមស្របសម្រាប់រក្សាបន្តឃុំខ្លួនបណ្ដោះអាសន្ន។ អង្គជំនុំជម្រះបានសម្រេចថា ការធានាអះអាងរបស់ជនជាប់ចោទ និងសមាជិក

---

*តុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E284** (“សេចក្ដីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី”)។

[11] សេចក្ដីសម្រេចលើសំណើសុំដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E275/1** (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”)។

[12] ដោយផ្អែកលើមូលដ្ឋាននៃវិធាន ១០៤ (៤) (ខ) នៃវិធានផ្ទៃក្នុង (“វិធានផ្ទៃក្នុង”)។

ក្រុមគ្រួសាររបស់គាត់ ពុំមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបំបាត់កង្វល់ទាំងនេះ ឬហានិភ័យដែលថា ជនជាប់ចោទអាចរត់គេចខ្លួននោះ។

១៤. ទង្វើបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសខាងអង្គច្បាប់ និងអង្គហេតុ ដោយហេតុថា៖ សេចក្តីសម្រេចរបស់ខ្លួនពុំមានអំណះអំណាងគ្រប់គ្រាន់ ហើយអង្គហេតុជាក់ស្តែងសម្រាប់គាំទ្រ ទឡ្ហីករណ៍របស់មេធាវីការពារក្តី ក៏ពុំត្រូវបានអង្គជំនុំជម្រះយកមកពិចារណាដែរ។ អង្គជំនុំជម្រះ បានសង្កត់ធ្ងន់ហួសហេតុទៅលើហានិភ័យនៃការរត់គេចខ្លួន និងទៅលើកង្វល់ពុំមាសមហេតុសម ផលនានាទាក់ទងនឹងការរៀបសំសវនាការ។ អង្គជំនុំជម្រះពុំបានផ្តល់ទំនុកចិត្តគ្រប់គ្រាន់ដល់ការ ធានាអះអាងពីសំណាក់ជនជាប់ចោទ និងសមាជិកក្រុមគ្រួសាររបស់គេ ហើយពុំបានពិចារណាលើ វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើងឡើយ។

## ក. **<u>ហានិភ័យនៃការរត់គេចខ្លួន</u>**

### ១. **<u>ហានិភ័យអរូបី</u>**

១៥. នៅឆ្នាំ ២០០៧ និងក្នុងដំណាក់កាលស៊ើបសួរទាំងមូល ការធានាថានឹងរក្សាលោក ខៀវ សំផន ឲ្យ ស្ថិតនៅក្រោមសំណាញ់នៃយុត្តិធម៌ ពុំដែលត្រូវបានគេលើកឡើងម្តងណាឡើយ ដើម្បីជាអំណះ អំណាងដល់ការសម្រេចឃុំខ្លួន និងបន្តឃុំខ្លួនលោកបណ្តោះអាសន្ននោះ[13]។

[13] សូមមើលជាអាទិ៍នូវសាលដីកានានារបស់អង្គបុរេជំនុំជម្រះ៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **C26/5/26** កថាខណ្ឌ ៣៩, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ឯកសារ **C26/9/12** កថាខណ្ឌ ៣០។ លក្ខខណ្ឌ នេះលេចឡើងជាលើកដំបូងនៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែ វាគ្រាន់តែជាលើកឡើងដដែលៗ និង គ្មានសំអាងហេតុអ្វីផ្សេងក្រៅពីសំអាងហេតុដែលតាមរយៈនោះ សំអាងហេតុនៃសេចក្តីសម្រេចពីមុនៗនៅតែរក្សាតម្លៃរបស់ ខ្លួនដដែល៖ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ **D427** កថាខណ្ឌ ១៦២៣-១៦២៤។

១៦. ដោយឡែក នៅឆ្នាំ ២០១១ អង្គជំនុំជម្រះបានយោងទៅលើលក្ខណវិនិច្ឆ័យនេះតែមួយគត់ដើម្បីសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ អង្គជំនុំជម្រះ“*យល់ឃើញថា ករណីដែលលោក ខៀវ សំផន អាចប្រឈមនឹងការផ្ដន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធនោះ ខៀវ សំផន អាចមានចេតនាកាន់តែខ្លាំងក្នុងការរត់គេចខ្លួន*”[14]។ នៅពេលសម្រេចលើបណ្ដឹងឧទ្ធរណ៍ តុលាការកំពូលបានឯកភាពជាមួយជនជាប់ចោទថា អង្គជំនុំជម្រះពុំបានបង្ហាញអំណះអំណាងគ្រប់គ្រាន់ក្នុងការចេញសេចក្ដីសម្រេចរបស់ខ្លួន[15]។

១៧. នៅឆ្នាំ ២០១៣ ទោះបីជាមានសេចក្ដីណែនាំពីសំណាក់តុលាការកំពូលក៏ដោយ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសឆ្គងដូចគ្នានោះទៀត។ ជាក់ស្ដែង តុលាការកំពូលធ្លាប់បានបន្ទោសដល់អង្គជំនុំជម្រះថា បានសង្កត់ធ្ងន់លើលក្ខណវិនិច្ឆ័យមួយនេះហួសហេតុពេក[16] ហើយតុលាការកំពូលក៏បានរំលឹកអង្គជំនុំជម្រះផងដែរថា ហានិភ័យដែលថាជនជាប់ចោទអាចប្រឈមនឹងការដាក់ទោសធ្ងន់ធ្ងរពុំអាចត្រូវបានគេចាត់ទុកក្នុងរូបភាពមិនជាក់ស្ដែង (*in abstracto*) ថាជាមូលហេតុដ៏សមហេតុសមផលក្នុងការបដិសេធចោលពាក្យសុំដោះលែងឱ្យស្ថិតនៅក្រៅឃុំនោះឡើយ[17]។ ដោយបានរំលឹកអំពីភារកិច្ចរបស់ចៅក្រម ក្នុងការ “*ពិចារណាទៅលើអង្គហេតុជាក់ស្ដែងដែលជនជាប់ចោទបានលើកឡើងដើម្បីជាមូលដ្ឋាន*” នៃទឡ្ហីករណ៍របស់ខ្លួន[18] តុលាការកំពូលក៏បានប្រកាសផងដែរថា៖

“រាល់តុលាការដែលទទួលបន្ទុកវាយតម្លៃអំពីនីត្យានុកូលភាព នៃការឃុំខ្លួនបណ្ដោះអាសន្នរបស់បុគ្គលម្នាក់ ត្រូវតែវាយតម្លៃរាល់មូលហេតុនៃការឃុំខ្លួន ហើយធ្វើការថ្លឹងថ្លែងអំពីហេតុផលនេះជាមួយនឹងសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានសេរីភាពបុគ្គល។ ដូចដែលតុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្សបានសម្រេចរួចហើយ ការបន្តរក្សាឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានផ្ដល់យុត្តិកម្ម តែដរាប

[14] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១ កថាខណ្ឌ ៥០។

[15] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពី ខៀវ សំផន កថាខណ្ឌ ៤០-៤២, ៥០, ៥៤។

[16] ដូចយោងខាងលើ កថាខណ្ឌ ៥១។

[17] ដូចយោងខាងលើ កថាខណ្ឌ ៥០។

[18] ដូចយោងខាងលើ កថាខណ្ឌ ៥៧។

ណាមាន ការចង្អុលបង្ហាញជាក់លាក់ថាការអនុវត្តបែបនេះពិតជាឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ ហើយថែមទាំងរំលោភលើវិធានទូទៅស្តីពីការដោះលែងឱ្យមានសេរីភាព។ ការបង្ហាញនូវហានិភ័យទូទៅនៃការរត់គេចខ្លួន ឬការរារាំងដល់ដំណើរការនីតិវិធីយុត្តិធម៌ មិនមានលក្ខណៈគ្រប់គ្រាន់នោះទេ។ ផ្ទុយទៅវិញ គេត្រូវពិចារណាលើហានិភ័យនោះ ដោយផ្អែកលើកាលៈទេសៈជាក់លាក់នៃរឿងក្តី (...)"[19]។

១៨. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានអះអាងថែមទៀតថា ហានិភ័យនៃការរត់គេចខ្លួន គឺជា "*សេចក្តីកង្វល់ចម្បង* "របស់ខ្លួន។ អង្គជំនុំជម្រះយល់ឃើញថា "*ទាដំណាក់កាលនៃការជំនុំជម្រះបច្ចុប្បន្ន ជនជាប់ចោទអាចជ្រើសរើសយកវិធីរត់គេចខ្លួន នៅពេលដែលដឹងថាខ្លួនអាចប្រឈមទៅនឹងការដាក់ទោសឱ្យជាប់ពន្ធនាគាររយៈពេលវែងនោះ* " (ឃ្លាទាំងមូលពុំមាននៅក្នុងសំណៅជាភាសាបារាំងនៃសេចក្តីសម្រេចឡើយ)។ ដោយឡែក អង្គជំនុំជម្រះពុំបានបកស្រាយទឡ្ហីករណ៍នេះទេ ដោយគ្រាន់តែយោងទៅលើសេចក្តីសម្រេចឆ្នាំ ២០១១ កាលពីពេលមុនរបស់ខ្លួននៅត្រង់កំណត់សម្គាល់ជើងទំព័រតែប៉ុណ្ណោះ។

១៩. បច្ចុប្បន្ននេះក៏ដូចជាកាលពីឆ្នាំ ២០១១ ដែរ អង្គជំនុំជម្រះមានបំណងលើកឡើងអំពីហានិភ័យ ដែលមានលក្ខណៈអរូបី ពោលគឺការវាយតម្លៃជាទូទៅតែម្តង។ បច្ចុប្បន្ននេះក៏ដូចជាកាលពីឆ្នាំ ២០១១ ដែរ អង្គជំនុំជម្រះពុំបានធ្វើការពិចារណាលើចរិតលក្ខណៈផ្ទាល់នៃសំណុំរឿង និងទៅលើអង្គហេតុជាក់ស្តែងនានាដែលត្រូវបានបង្ហាញនៅក្នុងទឡ្ហីករណ៍ពីសំណាក់ជនជាប់ចោទឡើយ។

## <u>២. អង្គហេតុជាក់ស្តែងនានាសម្រាប់គាំទ្រទឡ្ហីករណ៍របស់ជនជាប់ចោទ</u>

២០. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានសម្រេចយ៉ាងសមហេតុសមផលថា "*នៅក្នុងរឿងក្តីមួយចំនួន ចេតនាក្នុងការរត់គេចខ្លួន អាចថមថយទៅតាមការវិវត្តនៃពេលវេលា។ នៅក្នុងរឿងក្តីខ្លះទៀត ចេតនានោះអាចមិនមានការប្រែប្រួល*

[19] ដូចយោងខាងលើ កថាខណ្ឌ ៥៦។

*អ្វីឡើយ។ ហើយនៅក្នុងរឿងក្ដីមួយចំនួនផ្សេងទៀត ចេតនានេះមិនមានការវិវត្តខ្លាំងក្លារហូតដល់ថ្នាក់ចៅក្រមមិនអាចធ្វើការពិចារណាលើហេតុផលសម្រាប់ចេញសេចក្ដីសម្រេចផ្សេងទៀត ពាក់ព័ន្ធនឹងការសុំដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលើជនជាប់ចោទដដែលនោះទេ"*[20]។

២១. ជាទូទៅ យុត្តិសាស្ត្រអន្តរជាតិជម្រុញឲ្យមានការពិនិត្យលើកាលៈទេសៈបុគ្គល ទៅលើស្ថានភាពផ្ទាល់ខ្លួន និងទៅលើអាកប្បកិរិយានៃសាមីខ្លួនអ្នកស្នើសុំឲ្យមានការដោះលែងនៅក្រៅឃុំនោះ[21]។

២២. អង្គជំនុំជម្រះបានមើលស្រាលដល់ការណែនាំអស់ទាំងនេះ។

២៣. ជាមួយគ្នានេះ អង្គជំនុំជម្រះពុំដែលពិចារណាទៅលើអង្គហេតុដែលថា លោក ខៀវ សំផន ពុំមានមធ្យោបាយខាងសម្ភារៈសម្រាប់ឲ្យគាត់អាចរត់គេចខ្លួនបាននោះឡើយ។

២៤. ដោយឡែក មេធាវីការពារក្ដីធ្លាប់បានលើកឡើងរួចមកហើយថា លោក ខៀវ សំផន ពុំមានលិខិតឆ្លងដែន ពុំមានគេហដ្ឋាននៅបរទេស ពុំមានមធ្យោបាយហិរញ្ញវត្ថុសម្រាប់រត់គេចខ្លួន ហើយមិនត្រឹមតែប៉ុណ្ណោះ ក្នុងអាយុ ៨២ ឆ្នាំ របស់គាត់ គាត់ក៏ពុំមានកម្លាំងកាយដើម្បីធ្វើការរត់គេចខ្លួននោះដែរ[22]។

២៥. អង្គជំនុំជម្រះបានធ្វើមិនដឹងមិនឮអំពីទឡ្ហីករណ៍ទាំងនេះ ហើយថែមទាំងមិនបានធ្វើការសង្ខេបទឡ្ហីករណ៍ទាំងនេះនៅក្នុងផ្នែកនៃសេចក្ដីសម្រេចរបស់ខ្លួន ដែលជាផ្នែកមួយមានគោលដៅរំលឹកអំពី

---

[20] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងអ្នកផ្សេងទៀត* IT-05-87-AR65.2 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើការបដិសេធសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ក្នុងពេលវិស្សមកាលតុលាការនារដូវរងារ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ១៥, *រដ្ឋអាជ្ញា ទល់នឹង Popovic និងអ្នកផ្សេងទៀត* IT-05-88-AR65.3 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើការដោះលែង *Ljubomir Borovcanin* ឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ ១៤។

[21] សំណើសុំដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌ ២៤-២៦។

[22] សំណើសុំដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌ ២៩, ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/180.1** ទំព័រ ១០១ បន្ទាត់ ១៧-២៥ ទំព័រ ១០២ បន្ទាត់ ១-៥ និង ១៨-២១ ទំព័រ ១១០ បន្ទាត់ ២២-២៥ (ភាសាបារាំង)។

ទឡ្ហីករណ៍នានារបស់ភាគីនោះ[23]...។ ជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការឆ្លើយតបតិចតួចទៅនឹង ទឡ្ហីករណ៍ទាំងនោះ ក្នុងសេចក្តីសម្រេចរបស់ខ្លួនឡើយ។

២៦. ជាក់ស្តែង អង្គជំនុំជម្រះគ្រាន់តែមានបំណងធ្វើការសន្មតជាទូទៅមួយថា រាល់បុគ្គលទាំងឡាយ ដែលប្រឈមមុខទៅនឹងការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារធ្ងន់ធ្ងរ អាចនឹងមានចេតនារត់គេចខ្លួន។ អង្គជំនុំ ជម្រះពុំបានធ្វើការថ្លឹងថ្លែងរវាងបុរេវិនិច្ឆ័យដែលមានលក្ខណៈបែបទ្រឹស្តីសុទ្ធសាធនេះ ជាមួយនឹង ព័ត៌មានផ្ទាល់ខ្លួនដែលអង្គជំនុំជម្រះទទួលបានពីលោក ខៀវ សំផន នោះទេ។

២៧. ជាមួយគ្នានេះ នៅក្នុងសំណើសុំពីដំបូងរបស់ខ្លួន ក្រុមមេធាវីការពារក្តីបានរំលឹកថា នៅខណៈដែល លោក ខៀវ សំផន ពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយ ហើយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានគេបង្កើតរួចមកហើយ លោក ខៀវ សំផន ដែលដឹងខ្លួនថានឹងត្រូវបានទទួលរងការចោទប្រកាន់ពីតុលាការនេះ លោកបានបង្ហាញឆន្ទៈរបស់លោកជាសាធារណៈថា លោកនឹងត្រៀមខ្លួនឆ្លើយតបទៅនឹងការចោទប្រកាន់មកលើរូបលោក[24]។ មេធាវីការពារក្តីធ្លាប់បានរំលឹកផងដែរអំពីចំណងស្អិតរមួតរបស់លោកជាមួយក្រុមគ្រួសារ[25]។

២៨. អាកប្បកិរិយាពីដំបូងរបស់លោក ខៀវ សំផន មានលក្ខណៈខ្លាំងក្លា និងគួរឲ្យជឿជាក់ ជាងទ្រឹស្តីបែបអរូបី និងរាក់កំផែល ដែលយល់ឃើញថា រាល់ជនជាប់ចោទតែងតែរិះរកវិធីរត់គេចខ្លួននោះ។ លោក ខៀវ សំផន តែងតែមានបំណងចូលខ្លួនមកបំភ្លឺនៅចំពោះមុខតុលាការ។ អាកប្បកិរិយាជាទូទៅរបស់គាត់ (សេចក្តីថ្លែងការណ៍ជាសាធារណៈ ការផ្តល់បទសម្ភាស ការបោះពុម្ពផ្សាយសៀវភៅ ការផ្តល់កិច្ចសហការយ៉ាងពេញទំហឹងជាមួយអង្គជំនុំជម្រះ បើទោះបីជាលោកមានអាយុចាស់ណាស់ទៅហើយ) បានបង្ហាញឲ្យឃើញអំពីចេតនាគោរពដល់យុត្តិធម៌ និងឆន្ទៈក្នុងការយល់ និងពន្យល់។

---

[23] សេចក្តីសម្រេចដែលត្រូវបានជំទាស់ សូមមើលជាអាទិ៍កថាខណ្ឌ ៧-៨។

[24] សំណើសុំដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌ ២៨, ៦0, ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២0១៣ ឯកសារ **E1/180.1** ទំព័រ ៩៦ បន្ទាត់ ១0-១៦ ទំព័រ ១៣៤ បន្ទាត់ ៤-១៦ (ភាសាបារាំង)។

[25] សំណើសុំដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌ ២៩។

២៩. ដោយពុំបានពិចារណាលើកាលៈទេសៈបុគ្គល អង្គជំនុំជម្រះពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការពិនិត្យពិច័យឱ្យបានហ្មត់ចត់លើសំណើសុំដែលបានដាក់មកខ្លួនឡើយ។

## ៣. ការធានាដែលបានបង្ហាញឡើង

៣០. នៅកថាខណ្ឌ ២១ នៃសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានប្រកាសថា "*ការធានាពីសំណាក់ជនរងគ្រោះ និងសមាជិកក្រុមគ្រួសាររបស់ខ្លួនពុំទាន់ល្មមគ្រប់គ្រាន់នោះទេ*"។

៣១. ការយល់ឃើញដូច្នេះ គឺជារឿងមួយខុសឆ្គងសុទ្ធសាធ។

៣២. សមាជិកក្រុមគ្រួសាររបស់លោក ខៀវ សំផន បានផ្តល់ដល់អង្គជំនុំជម្រះនូវរាល់ភ័ស្តុតាងដែលបញ្ជាក់អំពីទីកន្លែងស្នាក់នៅនាពេលអនាគតរបស់ជនជាប់ចោទ។ ពួកគេក៏បានបង្ហាញផងដែរនូវឆន្ទៈស្វាគមន៍ជានិច្ចចំពោះរាល់ការចាប់ខ្លួននានាដែលមានលក្ខណៈស្របច្បាប់ និងអាចទទួលយកបាន[26]។

៣៣. លើសពីនេះ នៅក្នុងអត្ថបទដែលភ្ជាប់ទៅនឹងសំណើសុំដោះលែងឱ្យនៅក្រៅឃុំ លោក ខៀវ សំផន បានធ្វើការសន្យាជាឱឡារិកថា លោកនឹងបន្តបង្ហាញខ្លួននៅរាល់អង្គសវនាការរបស់ អ.វ.ត.ក. និងគោរពនូវរាល់វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការនានាដែលអនុវត្តមកលើរូបលោក[27]។ គាត់បានធ្វើការសន្យាបែបនេះដោយផ្ទាល់មាត់ជាច្រើនលើកច្រើនសានៅក្នុងពេលដែលមានសវនាការជាសាធារណៈពិនិត្យសម្រេចលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំនោះ[28]។ បណ្តាញផ្សព្វផ្សាយព័ត៌មានក៏បានចុះផ្សាយយ៉ាងគគ្រឹកគគ្រេងពីការសន្យានេះដែរ។

[26] សំណើសុំដោះលែងឱ្យនៅក្រៅឃុំ ឧបសម្ព័ន្ធ **E275.1**, **E275.2**, **E275.3**, **E275.5**, **E275.6**, **E275.7**, **E275.8**។
[27] សំណើសុំដោះលែងឱ្យនៅក្រៅឃុំ ឧបសម្ព័ន្ធ **E275.4**។
[28] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/180.1** ទំព័រ ១១១ បន្ទាត់ ១៧-២១ (ភាសាបារាំង)។

៣៤. បើយោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការណ៍ដែលជនជាប់ចោទព្រមព្រៀងទទួលយកនូវរាល់លក្ខខណ្ឌទាំងឡាយនៃការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន បង្ហាញឱ្យឃើញអំពីសុច្ចរិតភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក៏បានទទួលស្គាល់ផងដែរអំពីសារៈសំខាន់នៃអាកប្បកិរិយារបស់ជនជាប់ចោទ ក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី ដែលត្រូវបានចាត់ទុកថាជាគម្រូដល់ជនជាប់ចោទដទៃទៀត[29]។

៣៥. ជាក់ស្តែង ដោយហេតុថាការសម្រេចដោះលែងឱ្យនៅក្រៅឃុំទាមទារឱ្យមានការទុកចិត្តលើបុគ្គលដែលស្នើសុំ គេពុំមានដំណោះស្រាយណាមួយដែលងាយស្រួលជាងការឃុំខ្លួនជននោះបន្តទៀតឡើយ។ ហេតុដូច្នេះហើយ បានជាអង្គជំនុំជម្រះប្រហែលជាពិនិត្យលើហេតុផលទាំងឡាយដែលធ្វើឱ្យអង្គជំនុំជម្រះមិនអាចមានការទុកចិត្តលើលោក ខៀវ សំផន នោះ។ អង្គជំនុំជម្រះគ្រាន់តែបានធ្វើការសន្និដ្ឋានជាមុនបែបរាក់កំផែល ("រាល់ជនជាប់ចោទតែងតែមានបំណងរត់គេចខ្លួន") និងមិនបានពិចារណាលើអាកប្បកិរិយាជាទូទៅរបស់ជនជាប់ចោទ និងការច្រានចោលតថភាពជាក់ស្តែង ព្រមទាំងការធានាដ៏ហ្មឹងហ្មាត់របស់ជនជាប់ចោទ និងក្រុមគ្រួសារជនជាប់ចោទ។

៣៦. ធាតុផ្សំអស់ទាំងនេះហើយដែលត្រូវតែបានវាយតម្លៃដាច់ដោយឡែកពីគេ និងក្នុងលក្ខណៈប្លុកបញ្ចូលគ្នា។ ជាក់ស្តែង អង្គជំនុំជម្រះពុំបានធ្វើដូច្នោះឡើយ។

## ៤. វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើង

៣៧. នៅឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា៖

"*បើពិតមែនតែ អង្គជំនុំជម្រះសាលាដំបូងអាចនឹងសិក្សាឱ្យបានស៊ីជម្រៅលើលទ្ធភាពអនុវត្តវិធានផ្សេងៗក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន ដែលអាចធានាបានដូចឱ្យមានវត្តមានរបស់ជនជាប់ចោទនៅដំណាក់កាលជំនុំជម្រះ នោះសេចក្តីសម្រេចនេះនៅតែមានសុពលភាព ដោយហេតុថា សារណា*

---

[29] *រដ្ឋអាជ្ញា ទល់នឹង Galic* IT-98-29-A សេចក្តីសម្រេចលើសំណើសុំដោះលែង Stanislav Galic ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ១៦។

*ផ្ទាល់មាត់ និងលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ មិនបានផ្តល់នូវសេចក្តីលម្អិតដែលទាក់ទិននឹងមធ្យោបាយធានាវត្តមាននោះទេ* ”[30]។

៣៨. នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះក៏ពុំបានធ្វើការពិនិត្យលទ្ធភាពនេះដែរ នៅខណៈដែលមេធាវីការពារក្តីបានផ្តល់នូវសេចក្តីលម្អិតស្តីអំពីមធ្យោបាយនានា ដែលតាមរយៈនោះមេធាវីការពារបានស្នើដើម្បីធានាឱ្យមានវត្តមានរបស់លោក ខៀវ សំផន នៅពេលសវនាការ[31]។

៣៩. ដោយយោងទៅលើហេតុផលទាំងអស់នេះហើយ ក្នុងគោលជំហរដូចគ្នាទៅនឹងតុលាការកំពូលបារាំង[32]ដែរ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានពន្យាការឃុំខ្លួនបណ្តោះអាសន្ន ដោយពុំបានបញ្ជាក់អំពីហេតុផលដែលថាហេតុដូចម្តេចបានជាការធានាដែលបានផ្តល់តាមរយៈការត្រួតពិនិត្យតាមផ្លូវតុលាការ ពុំមានលក្ខណៈគ្រប់គ្រាន់នោះ។

៤០. អង្គជំនុំជម្រះមិនត្រឹមតែបានប្រព្រឹត្តនូវកំហុសឆ្គងផ្លូវច្បាប់ ក្នុងការដែលខ្លួនពុំបានលើកសម្អាងអំពីសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងចំណុចនេះប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមដែលប្រកបដោយសុភវិនិច្ឆ័យ គួរតែពិចារណាលើវិធានការនានាដែលបានស្នើឡើង ហើយដែលវិធានការទាំងនោះ មានលក្ខណៈគ្រប់គ្រាន់អាចធានាបានថា ជនជាប់ចោទនឹងមានវត្តមាននាពេលសវនាការ បើទោះបីជាមានហានិភ័យជាលក្ខណៈទ្រឹស្តី ដែលថាជនជាប់ចោទអាចរត់គេចខ្លួនក៏ដោយ ឬក៏មានកង្វល់ពាក់ព័ន្ធនឹងការរៀបចំសវនាការដែលពុំមានភាពសមហេតុសមផលក៏ដោយ។

## ២. __សេចក្តីកង្វល់ពាក់ព័ន្ធនឹងការរៀបចំសវនាការ__

[30] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥៨។

[31] សំណើសុំដោះលែងឱ្យនៅក្រៅឃុំ កថាខណ្ឌ ៥០-៥៣, ៥៧, ៥៨, ៦២, ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/180.1** ទំព័រ ១០១ បន្ទាត់ ៦-២៥ ទំព័រ ១០២ បន្ទាត់ ១-២១ ទំព័រ ១០៤ បន្ទាត់ ១៨-២៥។

[32] តុលាការកំពូល សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ រឿងក្តីលេខ ០៧-៨៨.៣៣៦ បោះពុម្ពផ្សាយក្នុងព្រឹត្តិប័ត្រ។

៤១. នៅកថាខណ្ឌ ២១ នៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានលើកឡើងអំពីហានិភ័យនៃការយឺតយ៉ាវផ្នែកនីតិវិធី ដែលអាចកើតឡើងបណ្តាលមកពីជនជាប់ចោទអវត្តមានដោយអចេតនា នាពេលសវនាការ។ អង្គជំនុំជម្រះពុំបានកំណត់អំពីបញ្ហា និងពុំបានពន្យល់ថាបញ្ហា នោះបណ្តាលមកអំពីអ្វី ហើយពុំបានពន្យល់ថាការពិចារណាទៅលើហានិភ័យដែលមានលក្ខណៈអរូបី និងពុំច្បាស់លាស់នេះ ពុំអាចឲ្យគេស្វែងរកដំណោះស្រាយឃើញក្រៅតែអំពីការបន្តឃុំខ្លួនបណ្តោះអាសន្ន ហើយហានិភ័យនេះអាចនឹងកើនឡើងខ្ពស់នៅពេលដែលមានការដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះឡើយ។

៤២. នៅក្នុងក្របខណ្ឌនៃនីតិវិធីបណ្តឹងសារទុក្ខនេះ មេធាវីការពារក្តីត្រូវបានជំរុញឲ្យធ្វើការបង្កើតសម្មតិកម្មនានា។

៤៣. ប្រសិនណាជាត្រូវពាក់ព័ន្ធនឹងបញ្ហាសុខភាពដែលអាចចោទឡើង ជនជាប់ចោទពុំមែនជាអ្នកដែលប្រឈមតែម្នាក់ឯងនោះទេ។ គេអាចនៅចាំបានថា កិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ពុំមែនត្រូវបានពន្យាពេលជាយថាហេតុ បណ្តាលមកអំពីបញ្ហាសុខភាពរបស់មេធាវីនោះទេ បញ្ហានេះបានកើតមានឡើងរួចទៅហើយ។ ជាឧទាហរណ៍ សាក្សីមួយរូប គឺលោក David CHANDLER ត្រូវលើកពេលវេលាចូលមកផ្តល់សក្ខីកម្ម ចំនួនពីរថ្ងៃ ដោយមូលហេតុសហព្រះរាជអាជ្ញាមួយរូបជួបប្រទះនូវបញ្ហាសុខភាព[33]។ ហេតុដូច្នេះ គេពុំអាចផ្តល់នូវអំណះអំណាងណាមួយដល់ការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ដែលត្រូវបានសន្មតថាគ្មានទោស ដោយគ្រាន់តែផ្អែកលើមូលដ្ឋានដែលពុំមានលក្ខណៈច្បាស់លាស់នោះឡើយ។

៤៤. ក្នុងគ្រប់ករណីទាំងអស់ អង្គជំនុំជម្រះពុំបានទទួលយកនូវវិធានការជាក់ស្តែងនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានស្នើឡើងដោយមេធាវីការពារក្តីនោះទេ។ ដោយឡែក វិធានការទាំងនោះមានគោលដៅទប់ស្កាត់ ក្នុងកម្រិតអតិបរិមា នូវរាល់ហានិភ័យនៃការមិនបង្ហាញខ្លួនដោយអចេតនាពី

---

[33] អ៊ីមែលរបស់លោកស្រី Susan LAMB កម្មវត្ថុ៖ « *Re: Co-Prosecutors Short Adjournment Request Regarding David Chandler* » ផ្ញើជូនភាគី នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ១២ និង ៤៨ នាទី ភ្ជាប់ក្នុងឧបសម្ព័ន្ធ។

សំណាក់ជនជាប់ចោទ ហើយវិធានការទាំងនេះមានប្រសិទ្ធិភាពដូចគ្នាទៅនឹងការធានាក្នុងករណីដែលជនជាប់ត្រូវបានបន្តឃុំខ្លួនបណ្តោះអាសន្ននោះ[34]។

៤៥. ជារួមមក អង្គជំនុំជម្រះពុំត្រឹមតែពុំបានអនុវត្តតាមគោលការណ៍ច្បាប់ដែលត្រូវអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែអង្គជំនុំជម្រះថែមទាំងពុំបានពិនិត្យលើធាតុផ្សំជាក់ស្តែងសមស្របដែលបង្ហាញដោយមេធាវីការពារក្តី មិនតែប៉ុណ្ណោះ បានសង្កត់ធ្ងន់តែទៅលើហានិភ័យដែលមានលក្ខណៈជាទ្រឹស្តី និងគ្មានមូលដ្ឋានច្បាស់លាស់។

៤៦. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងត្រូវបានចាត់ទុកជាមោឃៈ ហើយលោក ខៀវ សំផន នឹងត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

## ២. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

៤៧. នៅត្រង់កថាខណ្ឌ ២៣ នៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានចាត់ទុកថារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន "*មានលក្ខណៈសមហេតុសមផលនៅក្នុងគ្រប់កាលៈទេសៈទាំងអស់*"។

## គ. នីតិវិធីនៅក្នុងសំណុំរឿង ០០២

៤៨. បើយោងតាមអង្គជំនុំជម្រះ រហូតមកទល់នឹងពេលនេះ កិច្ចជំនុំជម្រះក្តីបានប្រព្រឹត្តទៅដោយគ្មានការយឺតយ៉ាវហួសហេតុនោះទេ ហើយគេអាចប្រមើលមើល ឬអាចមានភាពជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងថិរវេលាសរុបនៃការជំនុំជម្រះនេះ[35]។

---

[34] សំណើសុំដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌ ៥១, ៥៧, ៥៨, ៦១។

[35] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៣។

## ១. <u>ភាពយឺតយ៉ាវ</u>

៤៩. នៅត្រង់កថាខណ្ឌ ២៣ នៃសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានលើកឡើងថា បើប្រៀបធៀបទៅនឹង *"សំណុំរឿងនានាដែលមានលក្ខណៈស្មុគស្មាញប្រហាក់ប្រហែលទៅនឹងសំណុំរឿង ០០២"* *"នៅពេលដែលគ្រប់កាលៈទេសៈទាំងអស់ត្រូវបានពិចារណា (...) សំណុំរឿង ០០២ បានដំណើរការទៅមុខ ដោយពុំមានការយឺតយ៉ាវហួសហេតុនោះឡើយ"*។

៥០. **<u>ទីមួយ</u>** អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសឆ្គងខាងអង្គច្បាប់ ក្នុងការដែលអង្គជំនុំជម្រះពិចារណាតែទៅលើរឿងក្ដីនោះ នេះបើយើងនិយាយឲ្យចំ។

៥១. ជាក់ស្ដែង ផ្អែកទៅលើគោលការណ៍គតិយុត្តិដែលត្រូវអនុវត្ត ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នសំដៅផងដែរទៅលើថិរវេលាមុនដំណាក់កាលជំនុំជម្រះ និងចាប់ផ្ដើមបន្ទាប់ពីពេលដែលមានការឃុំខ្លួនបណ្ដោះអាសន្ន[36]។ អង្គជំនុំជម្រះពុំបានពិចារណាលើដំណាក់កាលនៃការស៊ើបសួរក្នុងចំណោម *"កាលៈទេសៈសមហេតុសមផល"* ទាំងឡាយ ដើម្បីវាយតម្លៃអំពីភាពយឺតយ៉ាវ នៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ។

៥២. ក្រៅពីនេះ អង្គជំនុំជម្រះពុំបានធ្វើការពិចារណាទៅលើទឡ្ហីករណ៍នានាដែលលើកដោយមេធាវីការពារក្ដី និងពុំបានផ្ដល់សម្អាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងបញ្ហាដែលបានលើកឡើងដោយមេធាវីការពារក្ដីឡើយ។ ជាក់ស្ដែង មេធាវីការពារក្ដីបានលើកឡើងអំពីភាពយឺតយ៉ាវ និងការមិនយកចិត្តទុកដាក់នាដំណាក់កាលស៊ើបសួរ[37] និងបានផ្ដល់នូវឯកសារភស្តុតាងនានាពាក់ព័ន្ធនឹងបញ្ហានេះ តាមរយៈសំណើសុំរបស់ខ្លួន[38]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះពុំមានបំណងពិចារ

---

[36] ឧទាហរណ៍ សូមមើល៖ រឿងក្ដី *Soria Valderrama ទល់នឹងប្រទេសបារាំង* បណ្ដឹងលេខ ២៩១០១/០៩ សាលដីកាតុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ២២-២៣។

[37] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/180.1** ទំព័រ ៩៤ បន្ទាត់ ២១-២៥ ទំព័រ ៩៥ បន្ទាត់ ១-២៥ (ភាសាបារាំង)។

[38] សំណើលើកទី១ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សា

បណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្ដីសម្រេចលើសំណើសុំ
ដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ណាលើសំណើសុំរបស់មេធាវីការពារក្តីនេះឡើយ ខណៈដែលខ្លួនមានកាតព្វកិច្ចត្រូវធ្វើការពិចារណា និងខណៈដែលខ្លួនមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពិចារណានោះ។

៥៣. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ សំណើសុំឱ្យមានការដាក់បញ្ចូលឯកសារភ័ស្តុតាងទៅក្នុងសំណុំរឿងនេះ ត្រូវបានជូនដំណឹងដល់ភាគីទាំងអស់។ នៅថ្ងៃទី ១៩ ខែ មេសា អង្គជំនុំជម្រះបានចាត់ទុកសំណើសុំនេះថាគ្មានកម្មវត្ថុ ហើយដែលសហព្រះរាជអាជ្ញាមានរយៈពេលរហូតដល់ថ្ងៃទី ២២ ខែ មេសា ដើម្បីធ្វើការឆ្លើយតប ហើយដែលអង្គជំនុំជម្រះមានរយៈពេលរហូតដល់ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ ដើម្បីចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់។ អង្គជំនុំជម្រះអាចនឹងធ្វើការពិចារណាបានយ៉ាងងាយស្រួលទៅលើឯកសារសំណេរអស់ទាំងនេះនៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។

៥៤. ការដែលធ្វើយ៉ាងដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសក្នុងការអនុវត្តនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ហើយកំហុសនេះបានបង្កើតឱ្យមានជាព្យសនកម្មធ្ងន់ធ្ងរដល់ម្ចាស់បណ្តឹង។ ធាតុផ្សំនៃភ័ស្តុតាងដែលបង្ហាញនៅក្នុងពាក្យបណ្តឹងនេះ មានលក្ខណៈសមហេតុសមផល និងគួរឱ្យជឿជាក់បាន ដោយហេតុថាធាតុផ្សំនៃភ័ស្តុតាងទាំងនោះបានមកអំពីចៅក្រមដែលដឹកនាំកិច្ច ស៊ើបសួរ។ ផ្អែកលើធាតុផ្សំនៃភ័ស្តុតាងទាំងនោះ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលប្រហែលមួយឆ្នាំ ដោយគ្មានហេតុផលអ្វីទាំងអស់។

៥៥. បើគិតអំពីភាពយឺតយ៉ាវនៃកិច្ចស៊ើបសួរ និងនៃការជំនុំជម្រះក្តី[39] ចៅក្រមដែលប្រកបដោយសុភវិនិច្ឆ័យអាចសន្និដ្ឋានបានថា ភាពយឺតយ៉ាវនេះមានលក្ខណៈហួសហេតុ។

៥៦. **ទីពីរ** អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសក្នុងការដែលប្រៀបធៀបរឿងដែលមិនអាចប្រៀបធៀបបាន...ជាក់ស្តែង ការណ៍ដែលប្រៀបធៀបរឿងក្តីបច្ចុប្បន្នជាមួយនឹង *"រឿងក្តីដទៃទៀតដែលមានភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា"* ពោលគឺរឿងក្តីដែលជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌ

ដេញដោល ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E280** កថាខណ្ឌ ៥-១៧។

[39] សំណើសុំដោះលែងឱ្យនៅក្រៅឃុំ កថាខណ្ឌ ១៣-១៨។

អន្តរជាតិ ប៉ុន្តែក្នុងក្របខណ្ឌនៃនីតិវិធីតតាំងក្តីតាមប្រព័ន្ធអង់គ្លូសាក់សុង គឺជារឿងមួយដែលមិនត្រឹមត្រូវ និងគ្មានតម្លៃទាល់តែសោះ។

៥៧. នៅខណៈដែលរឿងក្តីទាំងនោះត្រូវបានជំនុំជម្រះដោយគ្មានការស៊ើបសួរជាមុន និងដោយគ្មានការស្តាប់ចម្លើយរបស់សាក្សីនាដំណាក់កាលស៊ើបសួរ រឿងក្តីដែលត្រូវបានជំនុំជម្រះដោយអនុលោមតាមនីតិវិធីតតាំងក្តីក្នុងប្រព័ន្ធអង់គ្លូសាក់សុង នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាទូទៅមានរយៈពេលយូរជាងរឿងក្តីដែលមានការអនុវត្តនីតិវិធីស៊ើបសួរជាមុន ដែលនីតិវិធីនោះត្រូវបានចំណាយពេលអស់ជាច្រើនឆ្នាំ។ ក្នុងការប្រៀបធៀបរយៈពេលនៃការជំនុំជម្រះរឿងក្តីទាំងពីរប្រភេទនេះ ដើម្បីព្យាយាមប្រើប្រាស់ជាហេតុផលនៃការអូសបន្លាយការជំនុំជម្រះក្តីនាពេលបច្ចុប្បន្ន គឺជារឿងមួយដែលបង្កប់ដោយភាពមិនស្មោះត្រង់។

## ២. <u>ភាពដែលអាចប្រមើលមើលជាមុន និងភាពជាក់ច្បាស់</u>

៥៨. នៅត្រង់កថាខណ្ឌ ២៣ នៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា៖

*" បើទោះបីជាក្នុងករណីណាក៏ដោយ និងដោយហេតុថា សំណុំរឿង ០០២/០១ កំពុងឈានទៅរកដំណាក់កាលបញ្ចប់របស់ខ្លួន អង្គជំនុំជម្រះពុំឯកភាពជាមួយការលើកឡើងរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលថា ជនជាប់ចោទខ្វះលទ្ធភាពនៃការប្រមើលមើលឃើញ ឬភាពជាក់លាក់ទាក់ទងនឹងថិរវេលានៃការជំនុំជម្រះនេះឡើយ។"*

៥៩. ជាបឋម មេធាវីការពារក្តីសូមរំលឹកថា នៅខណៈដែលខ្លួនបានដាក់សំណើសុំដោះលែងឱ្យនៅក្រៅឃុំ សេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿងពុំទាន់ត្រូវបានចេញនៅឡើយទេ។ ក្រៅពីនេះ

មេធាវីការពារក្តីបានលើកអំណះអំណាងនៅក្នុងសំណើសុំនេះដោយពុំបានដឹងអំពីសម្អាងហេតុនៃសេចក្តីសម្រេចដែលត្រូវបានកែសម្រួល ហើយបានតវ៉ាប្រឆាំងទៅនឹងស្ថានភាពនេះ[40]។

៦០. អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចថ្មីរបស់ខ្លួនស្តីអំពីការបំបែកសំណុំរឿង ទន្ទឹមគ្នានឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យមានសេរីភាព។ ដោយឡែក ទោះបីជាសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿងមានលក្ខណៈវែងអន្លាយក៏ដោយ ក៏មានសំណួរជាច្រើនទាន់ពុំត្រូវបានឆ្លើយតបដែរ។ ភាពដែលអាចប្រមើលមើលជាមុន និងសន្តិសុខគតិយុត្តិ ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ក៏ពុំទាន់ត្រូវបានធានាដែរ។ ដូច្នេះ ទឡ្ហីករណ៍ដែលលើកឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន នៅតែមានសុពលភាពដដែល បើទោះបីជាមានការផ្តល់សម្អាងហេតុលើសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកនីតិវិធីក៏ដោយ[41]។ ភាពច្បាស់លាស់ដែលមេធាវីការពារក្តីមើលឃើញក្នុងពេលបច្ចុប្បន្ន នេះគឺថា នៅក្នុងសេចក្តីសម្រេចទាំងពីររបស់ខ្លួន អង្គជំនុំជម្រះបានលើកអំណះអំណាងផ្ទុយគ្នាទាំងស្រុង។

៦១. ជាបឋម នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានអះអាងថា ដោយមើលសំណុំរឿងទីមួយនៃរឿងក្តី ០០២ ខិតជិតមកដល់ទីបញ្ចប់ហើយ ជនជាប់ចោទអាចប្រមើលមើលអំពីថិរវេលានៃការជំនុំជម្រះរឿងក្តីរបស់ខ្លួនបាន។ ដោយឡែក នៅក្នុងសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿង អង្គជំនុំជម្រះបានអះអាងថា ទោះបីជាមានការបំបែកដីកាដំណោះស្រាយជារឿងក្តីតូចៗបន្តទៅទៀតនោះ ក៏ពុំមានបទចោទណាមួយដែលត្រូវបានដកចេញដែរ[42]។ ការជំនុំជម្រះរឿងក្តីរបស់លោក ខៀវ សំផន ពុំមែនមានតែទៅលើសំណុំរឿងទីមួយនៃ រឿងក្តី ០០២ នោះទេ។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានទទួលស្គាល់សមត្ថភាពរបស់លោក ខៀវ សំផន ដែលអាចប្រមើលមើលអំពីថិរវេលានៃរឿងក្តីទាំងមូល ដែលក្រសោបទៅលើបទចោទទាំងមូលដូចមាន

---

[40] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/177.1** ទំព័រ ២ បន្ទាត់ ៥-១៧ (ភាសាបារាំង)។

[41] សំណើសុំដោះលែងឱ្យនៅក្រៅឃុំ កថាខណ្ឌ ១៤-២៧។

[42] សេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១៥៥។

បញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[43]។ ដូច្នេះ អង្គជំនុំជម្រះផ្ទាល់ពុំមានសមត្ថភាពក្នុងការប្រមើលមើលអំពីថិរវេលាទាំងមូលនៃរឿងក្តីរបស់លោក ខៀវ សំផន ទេ។

៦២. បន្ទាប់មកទៀត នៅក្នុងសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿង អង្គជំនុំជម្រះបានលើកសម្អាងអំពីការបដិសេធរបស់ខ្លួនក្នុងការលាតសន្ធឹងវិសាលភាពនៃសំណុំរឿងទីមួយ រហូតដល់មន្ទីរ ស.២១ ដូចខាងក្រោម៖
*"ទោះជាយ៉ាងណាក្តី ហើយបើទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ការប៉ាន់ស្មានរបស់សហព្រះរាជអាជ្ញាក្តី ក៏អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ពេលវេលាចាំបាច់ដើម្បីបញ្ចប់សក្ខីកម្មដែលមានរយៈពេល ១៥ ថ្ងៃនេះ ទោះក្រោមលក្ខខណ្ឌនានាដែលអាចជំនះបាននៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ ក៏នៅតែអាចមានស្ថានភាពប្រែប្រួល និងមិនច្បាស់លាស់ជាខ្លាំង ដោយសារផលប៉ះពាល់នៃកត្តាជាច្រើន រួមទាំងសុខភាពរបស់ជនជាប់ចោទ លទ្ធភាពចូលខ្លួនរបស់សាក្សី និងដំណើរការនៃបណ្តឹងសារទុក្ខ។"*[44]។

៦៣. អង្គជំនុំជម្រះក៏បានលើកឡើងផងដែរអំពី *"ភាពមិនច្បាស់លាស់ ដែលភាគច្រើនមិនអាចដឹងជាមុនបាន"*[45] រួមទាំងភាពមិនច្បាស់លាស់នៃថវិការដែលធានាចាំបាច់ដល់ការប្រព្រឹត្តទៅនៃតុលាការ[46]៖

*"កត្តាមួយទៀតដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានការពាក់ព័ន្ធនោះ គឺភាពមិនច្បាស់លាស់ទាក់ទងនឹងរយៈពេលនៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ អ.វ.ត.ក. (...) រហូតមកទល់នឹងពេលនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលការឆ្លើយតប ឬការបញ្ជាក់ជាផ្លូវការណាមួយ*

---

[43] ដូចយោងខាងលើ កថាខណ្ឌ ១៥៥៖ *"(...) ប្រសិនបើជនជាប់ចោទទាំងពីរនៅមានសម្បទាគ្រប់គ្រាន់ និង អ.វ.ត.ក នៅបន្តទទួលថវិកាពីប្រទេសផ្តល់ជំនួយដើម្បីគាំទ្រដល់ការកាត់សេចក្តីនេះ នាពេលអនាគត"*, ឧបសម្ព័ន្ធ កំណត់សម្គាល់ជើងទំព័រ ២៧០ និង ២៧២៖ *"(...) កាលៈទេសៈដែលអំណោយផល និងលុះត្រាតែមានការណែនាំផ្សេងពីនេះ (...)"*, *"ទាំងអស់នេះគឺគ្រាន់តែជាការប្រមើលមើលប៉ុណ្ណោះ"*។

[44] ដូចយោងខាងលើ កថាខណ្ឌ ១៤០។

[45] ដូចយោងខាងលើ កថាខណ្ឌ ១៤២។

[46] ដូចយោងខាងលើ កថាខណ្ឌ ១២៥ (៥)។

*អំពីការបន្តផ្តល់ថវិការសម្រាប់ឆ្នាំ ២០១៣ និងដើមឆ្នាំ ២០១៤ នេះទេ (...) ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បញ្ហាថវិការដែលកំពុងកើតឡើងនៅ អ.វ.ត.ក ដែលបានដឹងជាសាធារណៈនេះ ទំនងជានឹងនៅបន្តកើតមាន (...)។"*[47]។

៦៤. ដូច្នេះ អង្គជំនុំជម្រះផ្ទាល់អសមត្ថភាពក្នុងការប្រមើលមើលឲ្យបានជាក់លាក់អំពីថិរវេលា ឬភាពវែងអន្លាយនៃរឿងក្តីនោះ។

៦៥. យើងអាចកត់សម្គាល់ឃើញថា រហូតមកទល់នឹងពេលនេះ ភាគីពុំបានដឹងអំពីចំនួន ឬអត្តសញ្ញាណនៃសាក្សីដែលអង្គជំនុំជម្រះមានបំណងនឹងកោះហៅឲ្យចូលខ្លួនមកចំពោះមុខសវនាការ មុនពេលធ្វើសេចក្តីសន្និដ្ឋានលើសវនាការដេញដោលលើអង្គសេចក្តីនៃសំណុំរឿងទីមួយឡើយ។ នៅក្នុងសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿងរបស់ខ្លួន អង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចប្រកបដោយសម្អាងហេតុគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ហានេះ ពេលក្រោយ[48]។

៦៦. ក្រៅពីនេះ ទោះបីជាអង្គជំនុំជម្រះបានអះអាងថា រឿងក្តីទីមួយបានខិតជិតមកដល់ទីចុងបញ្ចប់ក៏ដោយ ក៏អង្គជំនុំជម្រះពុំបានផ្តល់នូវការចង្អុលបង្ហាញណាមួយដែលអាចឲ្យភាគីទទួលបាននូវព័ត៌មានច្បាស់លាស់ពាក់ព័ន្ធនឹងថិរវេលាដែលនៅសេសសល់សម្រាប់បញ្ចប់រឿងក្តីទីមួយដែរ៖

*"អនុលោមតាមគោលការណ៍នានាដែលបានរៀបរាប់នៅក្នុងសេចក្តីសម្រេចនេះ សំណុំរឿង ០០២/០២ គួរចាប់ផ្តើមដំណើរការបន្ទាប់ពីបញ្ចប់សំណុំរឿង ០០២/០១ ទៅតាមកាលៈទេសៈដែលអំណោយផល និងលុះត្រាតែមានការណែនាំផ្ទុយពីនេះ។ ការប៉ាន់ស្មានពីសំណុំរឿង ០០១ បង្ហាញថា សាលក្រមនៅតុលាការថ្នាក់ដំបូងក្នុងសំណុំរឿងនេះ អាចបន្តរយៈពេលប្រហែល ០៨ ខែ ទៀត បន្ទាប់ពីបញ្ចប់សវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ (ពោលគឺ ក្នុងអំឡុង*

---

[47] ដូចយោងខាងលើ កថាខណ្ឌ ១៤៥-១៤៦, ១៥៥។

[48] ដូចយោងខាងលើ កថាខណ្ឌ ១៤៤។

*ត្រីមាសទី ១ នៃឆ្នាំ ២០១៤) និងសាលដីកាលើបណ្តឹងសាទុក្ខនឹងចេញ ១៨ ខែក្រោយ (ពោលគឺចុងឆ្នាំ ២០១៥)។ ទាំងអស់នេះគឺគ្រាន់តែជាការប្រមើលមើលប៉ុណ្ណោះ"*[49]។

៦៧. ការប្រមើលមើលនេះមិនត្រឹមតែមានលក្ខណៈទូលំទូលាយ និងចង្អុលបង្ហាញប៉ុណ្ណោះទេ ប៉ុន្តែវាមានលក្ខណៈខុសគ្នាអំពីការប្រមើលមើលរបស់អង្គជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការពិភាក្សាលើផលវិបាកដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការកំពូលស្តីអំពីការបំបែកសំណុំរឿង។ ជាក់ស្តែង លោកស្រីចៅក្រម FENZ បានរំលឹកថា អង្គជំនុំជម្រះត្រូវការរយៈពេល ៨ ខែ ដើម្បីចេញសាលក្រមលើសំណុំរឿង ០០១ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលត្រូវការរយៈពេល ១៨ ខែ ដើម្បីចេញសាលដីការបស់ខ្លួន។ ដោយឡែក លោកស្រីចៅក្រមបានបញ្ជាក់ ទៀតថា រឿងក្តី ០០១ គ្រាន់តែជារឿងក្តីដែលមានជនជាប់ចោទតែម្នាក់ ហើយពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មតែមួយកន្លែងប៉ុណ្ណោះ ចំណែកឯនៅក្នុងរឿងក្តី ០០២ វិញ មានជនជាប់ចោទច្រើននាក់ ដែលបង្កើតឱ្យមានជា "*ភាពស្មុគ្រស្មាញជាច្រើនខាងផ្លូវច្បាប់* " និងជាប់ពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មច្រើនកន្លែង។ លោកស្រីមានបំណងចង់ជម្រាបជូនភាគីឱ្យបាន "*យល់ច្បាស់អំពីការណ៍ដែលថា*"[50] ថិរវេលាជំនុំជម្រះលើសំណុំរឿង ០០២ នឹងយូរជាងថិរវេលាជំនុំជម្រះលើសំណុំរឿង ០០១។

៦៨. បន្ទាប់មកទៀត តាមរយៈសេចក្តីសម្រេចថ្មីស្តីអំពីការបំបែកសំណុំរឿង យើងសង្កេតឃើញថា អង្គជំនុំជម្រះនូវតែពុំមានសមត្ថភាពក្នុងការឆ្លើយតបទៅនឹងសំណួរដែលមានសារៈសំខាន់មួយចំនួនដែលជាហេតុធ្វើឱ្យភាគីនៃរឿងក្តីធ្លាក់ទៅក្នុងភាពអសន្តិសុខគតិយុត្តិទាំងស្រុង។ អង្គជំនុំជម្រះតុលាការកំពូលបានបន្ទោសដល់អង្គជំនុំជម្រះ ក្នុងការដែលអង្គជំនុំជម្រះពុំបានធ្វើការឆ្លើយតបទៅនឹងសំណួរទាំងនោះ "*ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នៃការជំនុំជម្រះក្តីក្នុងថិរវេលាមួយសមស្រប* " ហើយដែលអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថាជា "*ទង្វើដែលបង្កើតឱ្យមាន*

---

[49] ដូចយោងខាងលើ ឧបសម្ព័ន្ធ ទំព័រ ៧១ កំណត់សម្គាល់ជើងទំព័រ ២៧០។

[50] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E1/171.1** ទំព័រ ៣៩ បន្ទាត់ ១២-២៥ និងទំព័រ ៤០ បន្ទាត់ ១-២ (ភាសាបារាំង)។

*ព្យួរសេនក្ដ*ៈនោះ[51]។ កម្មវត្ថុចំបងរបស់អង្គជំនុំជម្រះតុលាការកំពូលគឺ "*ការពារនូវសិទ្ធិជាមូលដ្ឋាននៃរាល់ភាគីដែលពាក់ព័ន្ធ*"[52]។

៦៩. វាគឺជារឿងមួយដែលគួរឲ្យស្រឡាំងកាំង ក្នុងការដែលសន្និដ្ឋានថា អង្គជំនុំជម្រះពុំបានឆ្លើយតបទៅនឹងសំណួរទាំងនេះ ហើយបែរជាមានបំណងស្នើសុំឲ្យមានការរៀបចំកិច្ចប្រជុំរៀបចំសវនាការនាពេលក្រោយទៅវិញ[53]។

៧០. នៅក្នុងស្ថានភាពដែលភាពដែលអាចប្រមើលមើលជាមុនបាន និងសន្តិសុខគតិយុត្តិពុំត្រូវបានផ្ដល់ជូនភាគី វ័យជរារបស់ជនជាប់ចោទគឺជាកត្តាមួយដ៏មានសារៈសំខាន់បំផុតដែលត្រូវគិតគូរពិចារណា។

## ខ. __វ័យជរារបស់ជនជាប់ចោទ__

៧១. ផ្អែកតាមកថាខណ្ឌ ២៣ នៃសេចក្ដីសម្រេចដែលត្រូវបានជំទាស់៖

"*(...) អង្គជំនុំជម្រះយល់ឃើញថា វ័យជរារបស់ជនជាប់ចោទមិនមែនធ្វើឲ្យការឃុំខ្លួនគាត់មិនសមស្របនោះទេ។ កត្តាទាំងឡាយដែលផ្ដល់ភាពសមហេតុផលចំពោះការបន្តឃុំខ្លួនគាត់ មានភាពលើសលប់លើកត្តាផ្ទាល់ខ្លួនរបស់ជនជាប់ចោទ នៅពេលដែលអង្គជំនុំជម្រះធ្វើការពិចារណាអំពីបទដ្ឋាននៃការយកចិត្តទុកដាក់ដែលត្រូវបានផ្ដល់ទៅឲ្យជនជាប់ចោទ និងការគោរពសិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានផ្ដល់ឲ្យដោយមន្ទីរឃុំឃាំងនៃ អ.វ.ត.ក.*"។

---

[51] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៧។

[52] សេចក្ដីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន សុំឲ្យអង្គជំនុំជម្រះតុលាការកំពូលជូនដំណឹងជាបីភាសាផ្លូវការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E163/5/1/15** កថាខណ្ឌ ៧។

[53] សេចក្ដីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១៥៤-១៥៥។

៧២. គួររំលឹកផងដែរថា មេធាវីការពារក្តីពុំបានលើកឡើងថា វ័យចាស់ជរានៃជនជាប់ចោទគឺជាឧបសគ្គ នោះទេ។ ទឡ្ហីករណ៍របស់មេធាវីការពារក្តីលើចំណុចនេះ គឺចង់ធ្វើការកត់សម្គាល់ថា វ័យចាស់ជរា របស់ជនជាប់ចោទមានសារៈសំខាន់ជាខ្លាំងពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន បានសេចក្តីថា នៅខណៈដែលគោលការណ៍សច្ចាធារណ៍និរទោសនៅតែត្រូវបានគេអនុវត្ត ហើយជនជាប់ចោទពុំ បានដឹងថារឿងក្តីរបស់ខ្លួននឹងបញ្ចប់នៅពេលណានោះទេ (សូមអានកថាខណ្ឌខាងលើ)។

៧៣. បើពិចារណាទៅលើកត្តានៃភាពយឺតយ៉ាវ កង្វះលទ្ធភាពក្នុងការអាចប្រមើលមើលជាមុន និង កង្វះ សន្តិសុខគតិយុត្តិ ក៏ដូចជាវ័យចាស់ជរារបស់លោក ខៀវ សំផន ក្នុងករណីដែលកត្តាទាំងអស់នេះ រួមបញ្ចូលគ្នា បានធ្វើឲ្យថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើរូបលោក ខៀវ សំផន ក្លាយទៅ ជាមានភាពយូរហួសហេតុ។

៧៤. ប្រសិនណាជាគេអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍គតិយុត្តិ និងធ្វើការពិចារណាលើធាតុផ្សំ ភ័ស្តុតាងដែលមានភាពសមហេតុសមផល ចៅក្រមដែលប្រកបដោយសុភវិនិច្ឆ័យនឹងយល់ឃើញ ដូចគ្នា។

## ៣. ការវិវត្តនៃស្ថានការណ៍បន្ទាប់ពីសេចក្តីសម្រេចកាលពីពេលមុន

៧៥. នៅកថាខណ្ឌ ២៣ នៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះបានរំលឹកអំពីវិធាន ៨២(៤) នៃវិធានផ្ទៃក្នុង ដែលតាមរយៈនោះ ជនជាប់ចោទអាចដាក់សំណើសុំដោះលែងឲ្យនៅក្រៅ ឃុំបណ្តោះអាសន្នសាជាថ្មីបាន ប្រសិនណាជាស្ថានការណ៍មានការវិវត្តចាប់តាំងពីពេលដែលមាន សេចក្តីសម្រេចកាលពីពេលមុនពាក់ព័ន្ធនឹងបញ្ហានេះ។ អង្គជំនុំជម្រះបានបន្ថែមថា៖

"*អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយ បដិសេធមិនដោះលែងជនជាប់ចោទ ខៀវ សំផន កាលពីខែ កុម្ភៈ ឆ្នាំ ២០១១។ អង្គជំនុំជម្រះបាន រកឃើញថា មិនមានការផ្លាស់ប្តូរណាមួយចំពោះកាលៈទេសៈនានារបស់ជនជាប់ចោទ ចាប់ពី ពេលនោះមក ដែលអាចធ្វើឲ្យអង្គជំនុំជម្រះផ្តល់ការអនុញ្ញាតតាមសំណើសុំនាពេលនោះឡើយ*"។

៧៦. ម្យ៉ាងទៀតមានកំហុសឆ្គងពាក់ព័ន្ធនឹងកាលបរិច្ឆេទ ដោយហេតុថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានចេញកាលពីខែ មិថុនា ឆ្នាំ ២០១១ ហើយពុំមែនចេញនាខែ កុម្ភៈ ឆ្នាំ ២០១១ ទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសឆ្គងលើអង្គច្បាប់ ដោយហេតុថា វិធាន ៨២.៤ នៃវិធានផ្ទៃក្នុងពុំអាចយកមកអនុវត្តលើករណីនេះបានឡើយ។

៧៧. ជាក់ស្តែង នៅឆ្នាំ ២០១១ ដើម្បីប៉ះប៉ូវកំហុសឆ្គងក្នុងការណ៍ដែលពុំបានផ្តល់នូវពេលវេលា និងមធ្យោបាយចាំបាច់នានាដល់ភាគីក្នុងការត្រៀមរៀបចំសវនាការ អង្គជំនុំជម្រះបានប្រកាសថា វិធាន ៨២.៤ នឹងមិនត្រូវបានអនុវត្តទេក្នុងករណីដែលមានការដាក់សំណើសុំដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នសាជាថ្មីនោះ[54]។ នៅពេលសម្រេចលើបណ្តឹងសាទុក្ខ តុលាការកំពូលបានចាត់ទុកវិធានការនៃ "ការប៉ះប៉ូវ"នេះថាមានលក្ខណៈសមស្រប[55]។

៧៨. ហេតុដូច្នេះហើយ ការណ៍ដែលអង្គជំនុំជម្រះយោងលើវិធាន ៨២.៤ ដើម្បីបដិសេធចោលសំណើសុំដោះលែងឲ្យនៅក្រៅឃុំសាជាថ្មីរបស់លោក ខៀវ សំផន បង្ហាញឲ្យឃើញថាអង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសឆ្គងលើអង្គច្បាប់សាជាថ្មី។

## **<u>ហេតុដូច្នេះ</u>**

៧៩. មេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

- **បើក** សវនាការជាសាធារណៈមួយ
-**លុបចោល**សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងសំណើសុំដោះលែងជាបន្ទាន់របស់លោក ខៀវ សំផន
- **បង្គាប់ឲ្យ**មានការដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់

---

[54] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១ កថាខណ្ឌ ៤២។

[55] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥១ និង ៥៥។

- **ដាក់**ការដោះលែងឲ្យនៅក្រៅឃុំនេះក្រោមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលមានលក្ខណៈសមស្រប។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |